សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន
CAMBODIANS FOR RESOURCE REVENUE TRANSPARENCY

លេខ ០១
ខែវិច្ឆិកា ឆ្នាំ២០០៩

# ព្រឹត្តិបត្រព័ត៌មាន សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន

## សេចក្តីណែនាំអំពី សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន

កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ កន្លងទៅនេះ សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំនូលធនធាន ដែលហៅកាត់ថា ស៊ីអាអាធី (CRRT) បានសម្ពោធជាផ្លូវការរបស់ខ្លួនដោយមានអ្នកចូលរួមជាង ២០០នាក់។ ការចងជាសម្ព័ន្ធដោយអង្គការក្នុងស្រុកចំនួន៥ ស៊ីអាអាធី ជាតំណាងចលនាក្នុងប្រទេសកម្ពុជាដើម្បីតាមដានឃ្លាំមើលប្រាក់ចំណូលដែលនឹងទទួលបានពីវិស័យឧស្សាហកម្មនិស្សារណកម្ម រួមមាន ប្រេង ឧស្ម័ននិងរ៉ែ។




*ឆ្វេងទី១ លោកឆិត សំអាត សមាជិកក្រុមព្រឹក្សាភិបាលស៊ីអាអាធី ឆ្វេងទី២ ឯកឧត្តម ហង់ ជួនណារ៉ុន អគ្គលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឆ្វេងទី៣ លោកស្រី នាយិកានៃ អង្គការ ជេនឌឺ និងការអភិវឌ្ឍន៍ និងឆ្វេងទី៤ លោក អ៊ឹម សុភា សមាជិកក្រុមព្រឹក្សាភិបាលស៊ីអាអាធី*

ឯកឧត្តម **ហង់ ជួនណារ៉ុន** ជាអគ្គលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានថ្លែងនៅចំពោះមុខអ្នកចូលរួមដែលមានសមាសភាពមកពីអង្គការសង្គមស៊ីវិល និស្សិត ព្រះសង្ឃ អ្នកសារព័ត៌មាន អ្នកគ្រប់គ្រងជំនួញ និងអ្នកតំណាងសហគមន៍អន្តរជាតិជាច្រើនផ្សេងទៀតយ៉ាងដូច្នេះថា "របកគំហើញប្រេង និងឧស្ម័ននៅព្រះរាជាណាចក្រកម្ពុជាបាននាំមកនូវទាំងសេចក្តីរីករាយ និងទាំងក្តីព្រួយបារម្ភទៅលើការគ្រប់គ្រង និងតម្លាភាពចំណូលដែលបានមកពីវិស័យនេះ។"

ដោយយោងទៅលើការរកឃើញរបស់ក្រុមហ៊ុនឆេវរ៉ុន (Chevron) នៅក្នុងឆ្នាំ២០០៤ នូវបរិមាណប្រេង ដ៏ច្រើនមហិមានៅក្នុងឈូងសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម **ហង់ ជួនណារ៉ុន** បានបង្ហាញនូវអ្វីដែលរដ្ឋាភិបាលកំពុងតែរៀបចំខ្លួនដើម្បីធានាអោយបាននូវនិរន្តភាពនៃលំហូរទឹកប្រាក់ដែលទទួលបានពីការរុករក និងទាញយកប្រេងឧស្ម័ន ក៏ដូចជាអ្វីដែលរាជរដ្ឋាភិបាល នឹងគ្រប់គ្រងប្រាក់ចំណូលដែលទទួលបានពីវិស័យនេះ:

*សុទិដ្ឋិនិយមនៃផលិតកម្មប្រេង ឧស្ម័ន និងរ៉ែ នាពេលអនាគតបានបើកឱកាសថ្មីសម្រាប់ប្រែក្លាយកម្ពុជា អោយទៅជាមជ្ឈមណ្ឌលអភិវឌ្ឍន៍ថ្មីមួយនៅក្នុងតំបន់។ កាលានុវត្តភាពនេះ អាចអោយកម្ពុជារក្សាបាននិរន្តភាពនៃកំណើនសេដ្ឋកិច្ចខ្ពស់ សម្រាប់រយៈពេលមធ្យម និងវែង ក៏ដូចជាជំរុញអោយមានពិពិធកម្មសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រអោយបានលឿន។ ដើម្បីធានាការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងវិបុលភាពរបស់កម្ពុជា រាជរដ្ឋាភិបាលធានាគ្រប់គ្រងចំណូល ដោយតម្លាភាព និងប្រសិទ្ធភាព មានសារៈសំខាន់ក្នុងគណនេយ្យភាព និងអភិបាលកិច្ចល្អ នៅក្នុងឧស្សាហកម្មរ៉ែ ក៏ដូចជាដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងស្ថេរភាពនយោបាយ។*

នៅក្នុងយុទ្ធសាស្ត្រថ្មីរបស់រាជរដ្ឋាភិបាលកម្ពុជា នាពេលថ្មីនេះបានបែងចែកប្លុកប្រេងជា ២៦ប្លុក ទាំងក្នុងឈូងសមុទ្រ និងដែនគោក ក្នុងគោលបំណងដើម្បីអនុញ្ញាត្តិអោយក្រុមហ៊ុនប្រេងនានា អាចធ្វើការវិនិយោគលើវិស័យប្រេងនៅកម្ពុជា។ ការវិនិយោគទុនមកពីបរទេសបានហូរចូលមកប្រទេសកម្ពុជាជាសន្ទឹកសន្ទាប់ ហើយប្លុកនៅតាមតំបន់ឈូងសមុទ្រដ៏ធំ ត្រូវបានប្រគល់អាជ្ញាប័ណ្ណទៅអោយក្រុមហ៊ុនឆេវរ៉ុន (Chevron) ដែលធ្វើការសហការជាមួយក្រុមហ៊ុនរុករកប្រេង Mitsui របស់ប្រទេសជប៉ុន និងក្រុមហ៊ុន Caltex របស់កូរ៉េខាងជើង។ នៅខែកក្កដារដ្ឋលេខាធិការនៃទីស្តីការគណៈរដ្ឋមន្ត្រី ឯកឧត្តម **ប្រាក់ សុខុន** បានធ្វើការអះអាងថា ក្រុមហ៊ុនប្រេងដ៏ធំមកពីប្រទេសបារាំង គឺក្រុមហ៊ុនTotal ត្រូវបានផ្តល់អាជ្ញាប័ណ្ណអោយធ្វើការរុករកប្រេងនៅក្នុងតំបន់ត្រួតស៊ីគ្នាប្លុកទី៣ នៅក្នុងឈូងសមុទ្រថៃ។

ដោយមានការវិនិយោគពីបរទេសជាច្រើន ស៊ីអាអាធីបានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ដែលទាក់ទងទៅនឹងប្រាក់ចំណូលនានា ដែលទទួលបានពីធនធានធម្មជាតិ-ធនធាន ដែលមិនអាចកើតឡើងវិញដូចជាប្រេង ត្រូវតែយកទៅប្រើប្រាស់ក្នុងការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងជាអត្ថប្រយោជន៍ដល់ប្រជាជនកម្ពុជាគ្រប់ៗរូបនាពេលបច្ចុប្បន្នក៏ដូចជាពេលអនាគត។

"បន្តទៅទំព័រទី២"

### មាតិកា

- សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំនូលធនធាន........១-២
- សារតារសម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំនូលធនធាន..........................................................................២
- វេទិការសាធារណៈស្តីអំពី វិស័យស្សាហកម្មនិស្សារណកម្ម ធ្វើអោយកសិករនៅខេត្តបាត់ដំបងយល់ច្បាស់ពីតម្លៃប្រេង.........................................៣
- សន្ទានុក្រម...........................................................៤
- ប្រតិទិននៃសកម្មភាពរបស់អង្គការ ...........................៤

សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន
CAMBODIANS FOR RESOURCE REVENYE TRANSPARENCY

**ទស្សនៈវិស័យ**
ទស្សនៈវិស័យរបស់ CRRT គឺភោគទ្រព្យដែលបានមកពីឧស្សាកម្មនិស្សារណកម្មត្រូវមានការគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវផ្នែកសង្គមដែលមានតម្លាភាព គណនេយ្យភាពនិងការចូលរួមដើម្បីធ្វើឱ្យប្រជាពលរដ្ឋ កម្ពុជាគ្រប់រូប ទទួលបានផលចំណេញប្រកបដោយ សមធម៌។

# សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន

*"តពីទំព័រទី១"*

ទស្សនៈវិស័យរបស់ ស៊ីអាអាធី គឺភោគព្រទ្យដែលទទួលបានពីវិស័យឧស្សាហកម្មនិស្សារណកម្មត្រូវគ្រប់គ្រង ប្រកបដោយការទទួលខុសត្រូវផ្នែកសង្គមដែលមានតម្លាភាព គណនេយ្យភាព និងការចូលរួមដើម្បីធ្វើអោយប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានផលចំណេញប្រកបដោយសមធម៌។

បទពិសោធន៍ពីប្រទេសនានានៅលើពិភពលោក ជាពិសេសប្រទេសដែលសំបូរប្រេង ដូចជាប្រទេសអាហ្សែរបៃហ្សង់ និងប្រទេសទីម័រឡេស្តេ បានបង្ហាញពីការផ្លាស់ប្តូរជាវិជ្ជមាន ដែលអាចកើតមានសម្រាប់ប្រជាជនកម្ពុជាទាំងមូល។ ប្រសិនបើកម្ពុជាចាប់ផ្តើមងាកទៅរកការគ្រប់គ្រងចំនូលពីធនធាន ប្រកបដោយតម្លាភាព និងគណនេយ្យភាពនោះ នឹងជំរុញអោយមានកំណើនសេដ្ឋកិច្ច ស្ថេរភាពនយោបាយសក្តានុពលនៃការកើននៅក្នុងវិស័យវិនិយោគទុនឯកជន បង្កើនការចំណាយលើវិស័យសាធារណៈ ដើម្បីពង្រឹងវិស័យសុខភាពវិស័យអប់រំហេដ្ឋារចនាសម្ព័ន្ធនិងការកាត់បន្ថយភាពក្រីក្រ។




*លោកម៉ម សម្បត្តិ ប្រធានក្រុមប្រឹក្សាភិបាល នៃស៊ីអាអាធី និងលោក ស្តីវហ្វិន ហ្គីមបឺត មន្ត្រីនៃធនាគារពិភពលោក នៅក្នុងពិធីសម្ពោធជាផ្លូវការរបស់អង្គការស៊ីអាអាធ នៅសណ្ឋាគារសាន់វេ*

ឯកឧត្តម **ហង់ ជួនណារ៉ុន** បានថ្លែងប្រាប់វិទ្យុសំលេងសហរដ្ឋអាមេរិកជាភាសាខ្មែរថ្មីៗនេះថា "យើងសង្ឃឹមថានឹងទទួលប្រាក់ចំណូលពីប្រេង និងឧស្ម័ន នៅចន្លោះឆ្នាំ ២០១៣ និង២០១៥ នេះ"។

ដោយពេលវេលាខ្លី ដើម្បីរៀបចំខ្លួនក្នុងការគ្រប់គ្រងចំនូលពីធនធានទាំងនោះ ដូច្នេះយើងត្រូវតែចូលរួមជាមួយសម្ព័នភាព ស៊ីអាអាធុី អោយបានមុនពេលមានលំហូរទឹកប្រាក់ ដើម្បីជាការរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការធានានូវការប្រើប្រាស់ចំណូលប្រកបដោយតម្លាភាព និងគណនេយ្យភាព។

## សារតាររបស់សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន

សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន (ស៊ីអាអាធី) ត្រូវបានបង្កើតឡើងដោយអង្គការក្នុងស្រុក ចំនួនប្រាំ ដែលជាអង្គការមានគ្រឹះដ៏រឹងមាំក្នុងអង្គការសង្គមស៊ីវិលនៅប្រទេសកម្ពុជា មានដូចជា មជ្ឈមណ្ឌលសម្រាប់អភិវឌ្ឍន៍សង្គម អង្គការ អភិវឌ្ឍន៍ និងភាពជាដៃគូក្នុងសកម្មភាពវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងអង្គការ កម្មវិធីអភិវឌ្ឍន៍ធនធានយុវជន។




នៅក្នុងពិធីចុះហត្ថលេខាលើអនុសារណៈយោគយល់ កាលពីខែមករា ឆ្នាំ២០០៨ ស្ថាបនិកទាំងប្រាំ បានផ្តោតយ៉ាងសំខាន់ទៅលើប្រាក់ចំណូលដែលនឹងទទួលបានពី ប្រេង ឧស្ម័ន និងរ៉ែ សម្រាប់ការអភិវឌ្ឍន៍ប្រទេសជាតិនាពេលអនាគត ក៏ដូចជាបង្កើតអោយមានការចូលរួមក្នុងលក្ខណៈស្ថាបនាជាមួយរាជរដ្ឋាភិបាលកម្ពុជានិងវិស័យឯកជន ដើម្បីធានាថាប្រាក់ចំណូលដែលនឹងទទួលបានពីវិស័យឧស្សាហកម្មនិស្សារណកម្ម ត្រូវបានគ្រប់គ្រងបានយ៉ាងល្អ និងប្រកបដោយតម្លាភាព ក្នុងន័យដែលថា ព័ត៌មានពីការគ្រប់គ្រងលើវិស័យនេះ អាចអោយសាធារណជនយល់ បានច្បាស់លាស់។ ស៊ីអាអាធី ត្រូវបានចុះឈ្មោះ និងទទួលស្គាល់ដោយក្រសួងមហាផ្ទៃ កាលពីថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០០៩ កន្លងទៅនេះ។

សម្ព័ន្ធភាពនេះមានជំនឿថា:

- ប្រជាពលរដ្ឋទទួលបានព័ត៌មាន និងចូលរួមនៅក្នុងការពិភាក្សាដោយបើកចំហរដើម្បីចូលរួមក្នុងការធ្វើសេចក្តីសម្រេច ទៅលើការគ្រប់គ្រងហិរញ្ញវត្ថុនៃចំណូលដែលបានមកពីឧស្សាហកម្មនិស្សារណកម្ម។
- ព័ត៌មានស្តីពីការរុករកធនធាននិស្សារណកម្ម និងចំណូលដែលទទួលបានត្រូវផ្សព្វផ្សាយយ៉ាងទូលំទូលាយដើម្បីជួយសម្រួលដល់ការឃ្លាំមើលរបស់សាធារណជននៅក្នុងវិស័យនេះ។
- ចំណូលដែលបានមកពីឧស្សាហកម្មនិស្សារណកម្មត្រូវបានប្រើប្រាស់យ៉ាងសមស្របនិងមានប្រសិទ្ធភាពសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋទាំងពេលបច្ចុប្បន្ននិងក្នុងពេលអនាគត។

# វេទិការសាធារណៈស្តីអំពី វិស័យឧស្សាហកម្មនិស្សារណកម្ម ធ្វើអោយកសិករនៅខេត្តបាត់ដំបង យល់ច្បាស់ពីតម្លៃប្រេង




*សមាជិកក្រុមព្រឹក្សាភិបាលស៊ីអារអាធី កំពុងធ្វើបទបង្ហាញនៅក្នុងវេទិកាសាធារណៈខេត្តបាត់ដំបង*

ក្នុងវ័យ ៥៥ ឆ្នាំ **លោកឡៃ រីច** សក់សលាយខ្មៅ និងមានស្នាមជាំនៅលើផ្ទៃមុខដោយសារកំដៅថ្ងៃ បានសម្តែងនូវក្តីរំពឹងទុករបស់ខ្លួនថា "ខ្ញុំសង្ឃឹមទុកថា នៅពេលដែលស្រុកយើងអាចទាញយកប្រេងបាន ពេលនោះតម្លៃប្រេងក្នុងប្រទេសយើងប្រាកដជានឹងចុះថោកជាមិនខាន"។

បុរសជាកសិកររូបនេះ រស់នៅក្នុងស្រុកបាណន់ ខេត្តបាត់ដំបង បានបន្ថែមទៀតថា កសិករ នឹងមិនមានការព្រួយបារម្ភណ៍ចំពោះតម្លៃប្រេងទៀតឡើយ។ លោក **ឡៃ រីច** បាននិយាយទាំងទឹកមុខញញឹមលេចចេញនូវស្នាមជ្រួញ ជាច្រើនលើមុខយ៉ាងដូច្នេះថា "ខ្ញុំនឹងអាចមានលទ្ធភាពគ្រប់គ្រាន់ដើម្បីបូមទឹកដាក់ស្រែរបស់ខ្ញុំ"។

ក៏ប៉ុន្តែ ក្តីសង្ឃឹមរបស់កសិកររូបនេះ ត្រូវរលាយបាត់ទៅវិញ បន្ទាប់ពីលោកបានចូលរួមវេទិការសារធារណៈពេញមួយព្រឹក កាលពីថ្ងៃ ទី២៥ ខែកញ្ញា កន្លងទៅនេះ នៅឯសាលមហោស្រពស្ទឹងសង្កែ ខេត្តបាត់ដំបង ដែលបានរៀបចំឡើង ដោយអង្គការ សម្ព័ន្ធភាពកម្ពុជា ដើម្បីតម្លាភាពចំណូលធនធាន។

លោក **អ៊ឹម សុភា** សហប្រធានមជ្ឈមណ្ឌលយុត្តិធម៌ និងសម្របសម្រួលបានមានប្រសាសន៍នៅក្នុងវេទិកានេះថា "តម្លៃប្រេង ត្រូវបានកំណត់រួចជាស្រេចដោយ អង្គការបណ្តាប្រទេសនាំប្រេងចេញ OPEC។ ដូច្នេះ ប្រសិនបើប្រទេស យើងអាចទាញយកប្រេងមកប្រើប្រាស់បាននោះ តម្លៃប្រេងរបស់ប្រទេសយើង នឹងដូចតម្លៃប្រេង នៅលើទីផ្សារអន្តរជាតិដែរ"។

វេទិកាសាធារណៈដែលស្តីអំពី ការលើកកំពស់ការយល់ដឹងរបស់សាធារណជនលើវិស័យឧស្សាហកម្មនិស្សារណកម្ម ទទួលបានការឧបត្ថម្ភអង្គការ ហេនរេចបូល ស្ទីហ្វទង់ កម្ពុជា (HEINRICH BÖLL STIFTUNG) អង្គការជំនួយនៃប្រជាពលរដ្ឋ ន័រវេស្សន៍ (Norwegian People’s Aid) អង្គការ អុកស្វាមអាមេរិក (Oxfam America) និងត្រូយែរ (Trocaire) ក្នុងគោលបំណងដើម្បីចែករំលែកនូវចំណេះដឹង និងបទពិសោធន៏ជាមួយអ្នកចូលរួម ផ្តល់ឱកាសដល់អ្នកចូលរួម ដើម្បីធ្វើការពិភាក្សា និងលើកយកច្បាប់ដែលស្តីអំពី ការគ្រប់គ្រងនិងការទាញយករ៉ែ និងច្បាប់ពាក់ព័ន្ធផ្សេងៗមកបង្ហាញ។

វេទិកានេះ ក៏បានចែករំលែកនូវព័ត៌មានករណីសិក្សានៅក្នុងខេត្តរតនគីរី មណ្ឌលគីរី និងបណ្តារប្រទេស ផ្សេងៗទៀត ព្រមទាំងការស្វែងរកការសហការជាមួយបណ្តារក្រសួង មន្ទីរ និងស្ថាប័នដែលពាក់ព័ន្ធ និងការគាំទ្រពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ផងដែរ។

លោក **សោម វីរៈតារា** ប្រធានប្រតិបត្តិនៃអង្គការ ព្រះគ្រីស្តដើម្បីការអភិវឌ្ឍន៏កម្ពុជាCDK បានមានប្រសាសន៏ នៅក្នុងកិច្ចស្វាគមន៏ចំពោះអ្នកចូលរួមវេទិកាសាធារណនេះថា "វេទិកាលើកកម្ពស់ការយល់ដឹងនេះ គឺជាការអប់រំប្រជាជននៅតាមមូលដ្ឋានអំពីធនធានធម្មជាតិ ដើម្បីធានាអោយបាននូវការគោរពសិទ្ធិដោយអនុញ្ញាតិអោយ ប្រជាពលរដ្ឋទទួលបានព័ត៌មានអំពីការគ្រប់គ្រង និងផលប្រយោជន៏។" លោកក៏បានបន្ថែមផងដែរថា "វេទិកានេះ ក៏នឹងបានជួយផ្សព្វផ្សាយជូនប្រជាជន អំពីវិស័យឧស្សាហកម្មនិស្សារណកម្ម ការទាញយកធនធាន ការគ្រប់គ្រងប្រាក់ចំណូល និងការប្រើប្រាស់ចំណូលពីធនធានទាំងនេះក្នុងគោលដៅអភិវឌ្ឍន៏ប្រទេសជាតិ"។

លោក **សួន សារិន** អភិបាលរងស្រុកឯកភ្នំ ក៏បានមានប្រសាសន៏នៅក្នុងពិធីបើកវេទិការនេះ ដើម្បីបានលើកទឹកចិត្តដល់អ្នកចូលរួមទាំងអស់ប្រមាណ ២៥០ នាក់ ចូលរួមពិភាក្សាអោយបានទូលំទូលាយ ដើម្បីប្រមូលបានអនុសាសន៏ល្អៗដាក់ជូនរាជរដ្ឋាភិបាលដើម្បីអោយមានការសម្រេចចិត្តត្រឹមត្រូវក្នុងការរៀបចំផែនការអភិវឌ្ឍន៏ជាតិ។

លោកអភិបាលរងស្រុកបានបន្ថែមទៀតថា "ប្រជាជនកម្ពុជាគ្រប់រូបត្រូវតែព្យាយាមអោយអស់ពីសម្ថភាព ក្នុងការស្វែងយល់ពីឧស្សាហកម្មរ៉ែ ដើម្បីអភិវឌ្ឍន៏ចំណេះដឹងរបស់ខ្លួនក្នុងករណីក្រុមហ៊ុនត្រូវការយើង ក៏ប៉ុន្តែយើងក៏មិន ប្រាកដទេថាតើក្រុមហ៊ុននឹងត្រូវការយើងរឺក៏អត់នោះទេ។ទោះបីជាយ៉ាងណាក៏យើងត្រូវត្រៀមខ្លួនទុកជាមុន"។

លោក **ឡៃ រីច** បានសារភាពបន្ទាប់ពីលោកបានចូលរួមវេទិកានេះអស់មួយព្រឹករួចមកថា គាត់ហួសចិត្តចំពោះការយល់ឃើញរបស់ខ្លួនចំពោះបញ្ហាតម្លៃប្រេង។ លោក បានបន្ថែមព្រមជាមួយនឹងការដកដង្ហើមធំយ៉ាងវែងថា "ខ្ញុំយល់ច្រឡំ ចំពោះតម្លៃប្រេង។ ខ្ញុំ នឹងពាំនាំដំណឹង នូវអ្វីដែលខ្ញុំអាចចងចាំបានពីវេទិកានេះទៅពន្យល់ប្រាប់ក្រុមគ្រួសារ មិត្តភក្តិ ក៏ដូចជាអ្នកភូមិផ្សេងទៀតផងដែរ"។

យោងតាមរបាយការណ៏របស់វេទិកានេះ បានបង្ហាញអោយឃើញថា អ្នកចូលរួមទាំងអស់ទាមទារអោយមានវេទិកានេះម្តងទៀត ហើយអាចផ្តល់ពេលវេលាវែងជាងនេះក្នុងការពិភាក្សា និងសូមរៀបចំធ្វើនៅតាមសហគមន៏ឆ្ងាយៗ។

# សន្ទានុក្រម

១. **គណនេយ្យភាព** : ជាកាតព្វកិច្ចរបស់អាជ្ញាធររដ្ឋាភិបាល និងក្រុមហ៊ុនឯកជនពាក់ព័ន្ធនានាក្នុងការផ្តល់នូវការពន្យល់ ឬផ្តល់យុត្តិកម្មអំពីការសម្រេចចិត្ត និងសកម្មភាពរបស់ខ្លួននៅក្នុងការគ្រប់គ្រងភោគទ្រព្យដែលបានមកពីឧស្សាហកម្មនិស្សារណកម្ម ដោយពិចារណាផងដែរពីសេចក្តីត្រូវការ ការព្រួយបារម្ភ សមត្ថភាព និងផលប្រយោជន៍គ្រប់ភាគីពាក់ព័ន្ធទាំងអស់។

២. **ការចូលរួមប្រកបដោយលក្ខណៈស្ថាបនា** : ការចូលរួមជាលក្ខណៈស្ថាបនាទទួលស្គាល់ពីតួនាទីជាវិជ្ជមានរបស់ប្រជាពលរដ្ឋ និងសហគមន៍នៅក្នុងដំណើរការគ្រប់គ្រងចំណូលរបស់រដ្ឋាភិបាល។

៣. **កិច្ចសន្យា** : ជាកិច្ចព្រមព្រៀងផ្នែកច្បាប់រវាងរដ្ឋាភិបាល ដែលជាអ្នកកាន់កាប់សិទ្ធិស្របច្បាប់ លើធនធានធម្មជាតិដែលមិនអាចកកើតឡើងវិញបាន នៅក្រោមដី និងសមុទ្រ ជាមួយនឹងក្រុមហ៊ុន ឧស្សាហកម្មនិស្សារណកម្មឯកជន ដែលផ្តល់លទ្ធភាពឱ្យក្រុមហ៊ុនធ្វើការរុករកនិងផលិតធនធានឧស្សាហកម្មនិស្សារណកម្មនៅក្នុងតំបន់ភូមិសាស្ត្រដែលត្រូវបានអនុញ្ញាតសម្រាប់ពេលវេលាកំណត់មួយ ជាថ្នូរមកវិញនូវការបង់ថ្លៃជាក់លាក់ជាសាច់ប្រាក់ ឬជារបស់ (ឧទាហរណ៍ជាប្រេង)។ នៅក្នុងឧស្សាហកម្ម ប្រេងមានកិច្ចសន្យាប្រេងពីរប្រភេទធំៗ គឺ កិច្ចសន្យាបែងចែកផលិតផល និង កិច្ចសន្យាសម្បទាន។

៤. **ចំណូលដែលទទួលបាន** : ការលក់ធនធានធម្មជាតិក្រោយពេលដែលធ្វើនិស្សារណកម្មបង្កើតបានជាចំណូលដល់ក្រុមហ៊ុនដែលពាក់ព័ន្ធ និងរាជរដ្ឋាភិបាលកម្ពុជាតាមរយៈចំណូលពីការបង់ពន្ធ ថ្លៃសួយសារអាករ និងប្រាក់រង្វាន់ចុះហត្ថលេខា ដើម្បីបានសិទ្ធិធ្វើការរុករកជាដើម។

៥. **ឧស្សាហកម្មនិស្សារណកម្ម** : ឧស្សាហកម្មទាំងឡាយណាដែលធ្វើសកម្មភាពរុករក និងផលិតធនធានធម្មជាតិដែលមិនអាចកកើតឡើងវិញបាន ដូចជា រ៉ែ ប្រេងកាតឧស្ម័នធម្មជាតិ និងធនធានរ៉ែផ្សេងៗទៀតនៅក្រោមដី។

៦. **ធនធាន** : ជាធនធានរ៉ែដូចជា ប្រេងកាត ឧស្ម័នធម្មជាតិ និងធនធានរ៉ែផ្សេងៗទៀត ដែលអាចយកចេញពីបរិស្ថានធម្មជាតិ-មាននៅក្រោមដី ឬក្រោមសមុទ្រ... ដើម្បីបានផលចំណេញ។

៧. **ចំណូលដែលបានមកពីឧស្សាហកម្មនិស្សារណកម្ម** : គ្រប់ចំណូលរបស់រដ្ឋាភិបាលដែលបានមកពីការរុករក ការអភិវឌ្ឍ និងផលិតកម្ម ប្រេង ឧស្ម័ន និងរ៉ែដែលបានមកពីក្រុមហ៊ុនពាកពាកព័ន្ធទាំងអស់ ដូចជា ក្រុមហ៊ុនរ៉ែ និងប្រេងកាតអន្តរជាតិ ក្រុមហ៊ុនប្រេងជាតិនិងក្រុមហ៊ុនឯកជនក្នុងស្រុក។ចំណូលរដ្ឋាភិបាលដែលបានមកពីឧស្សាហកម្មនិស្សារណកម្មរួមមាន : ចំណូលពន្ធ សួយសារអាករ ចំណែករបស់រដ្ឋាភិបាលនៅក្នុងកិច្ចព្រមព្រៀងបែងចែកផលិតផល ប្រាក់រង្វាន់ ថ្លៃជួលផ្ទៃដី ឬជួលផ្ទៃសមុទ្រ ផលលាភក្រុមហ៊ុនប្រេងជាតិ ពន្ធគយ ប្រាក់ពិន័យ ប្រាក់ទណ្ឌកម្ម និងវិភាគទានផ្សេងទៀតជាសាច់ប្រាក់។

៨. **ការទទួលខុសត្រូវសង្គម** : គឺជាករណីយកិច្ចរបស់រដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិល ធ្វើការសម្រេចចិត្ត និងចាត់វិធានការណ៍ដែលលើកកម្ពស់សុខមាលភាព និងផលប្រយោជន៍សង្គមទាំងមូល។

៩. **ការអភិវឌ្ឍប្រកបដោយនិរន្តរភាព** : ការប្រើប្រាស់ភោគទ្រព្យធម្មជាតិ ដើម្បីអនុវត្តគោលនយោបាយសេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន ដែលបន្តផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋទាំងមូលទាំងពេលបច្ចុប្បន្ន និងអនាគត។

១០. **តម្លាភាព** : ជាយន្តការមួយ ដើម្បីលើកកម្ពស់គណនេយ្យភាព ដោយដាក់បង្ហាញជាសាធារណៈនូវព័ត៌មានដែលទាក់ទងនឹងលទ្ធផល និងការធ្វើសេចក្តីសម្រេចចិត្តរបស់ទីភ្នាក់ងាររដ្ឋាភិបាល និងក្រុមហ៊ុននិស្សារណកម្មឱ្យបានទាន់ពេលវេលា ត្រឹមត្រូវ និងគ្រប់ជ្រុងជ្រោយ ។ គោលការណ៍តម្លាភាព ឈានហួសពីការផ្តល់ការពិត និងតួលេខ ជាមូលដ្ឋានទៅដល់ការរួមបញ្ចូលនូវយន្តការ និងដំណើរការដែលបានប្រើប្រាស់ក្នុងការធ្វើសេចក្តីសម្រេចចិត្តផងដែរ។

## ប្រតិទិននៃសកម្មភាពរបស់អង្គការ

***ថ្ងៃទី១៥ ខែធ្នូ:***

**អ្វី:** វេទិកាតាមខេត្តរបស់ ស៊ីអារអាធី ស្តីអំពី ការលើកកម្ពស់ការយល់ដឹងរបស់សាធារណៈជនលើវិស័យឧស្សាហកម្មនិស្សារណកម្ម នៅប្រទេសកម្ពុជា
**នៅកន្លែងណា:** នៅទីរួមខេត្តមណ្ឌលគិរី (សាលប្រជុំអរុណរះ រីផ្ទះសំណាក់អរុណរះ)
**នៅម៉ោងប៉ុន្មាន:** ចាប់ផ្តើមពីម៉ោង ៧:៣០ នាទីព្រឹករហូតដល់ម៉ោង ១៥:00
**ចុះឈ្មោះដោយរបៀបណា:** សូមធ្វើការទំនាក់ទំនងមកកាន់មន្ត្រីទំនាក់ទំនងរបស់ស៊ីអារអាធីៈ

**លោក ប៉ាវ រតនា**
ទូរសព្ទលេខ: ៨៥៥-(0)-១២ ៣១៨ ១១៨
លេខការិយាល័យ: ៨៥៥-(0)-២៣ ២១៧ ៦0៧
អ៊ីម៉ែល: crrtcommunications@yahoo.com
គេហទំព័រ: crrt-cambodia.org.kh

## អាស័យដ្ឋានសកម្មភាពរបស់អង្គការ

បន្ទប់ ៤៨៥ អាគារ F មជ្ឈមណ្ឌលភ្នំពេញ កែងផ្លូវលេខ ២៧៤/៣ រាជធានីភ្នំពេញ ប្រទេសកម្ពុជា

ទូរស័ព្ទ: (855) 23 217 607

អ៊ីម៉ែល: crrtcommunications@yahoo.com

គេហទំព័រ: crrt-cambodia.org.kh